# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌
លេខ ២២ អគ្គ/២០០៥

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោក ចាប ម៉េងសែ ចៅក្រមតុលាការក្រុងភ្នំពេញ**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីសិទ្ធិប្ដឹងទាស់របស់គូភាគី ឬមេធាវីតំណាងភាគីនៃរឿងក្ដី ។
**យោង:** លិខិតលេខ ១០១០.រប-៩២១ ចុះថ្ងៃទី២៣-១២-២០០៤ របស់លោក ។

ខ្ញុំសូមជម្រាបលោកថា ផ្អែកតាមខ្លឹមសារនៃលិខិតរបស់លោក ដែលមានយោងខាងលើបញ្ជាក់ថា នៅពេលសវនាការភាគីដើមចោទ និងចុងចម្លើយ រួមជាមួយមេធាវីតំណាងឱ្យចុងចម្លើយបានចូលមកចំពោះមុខតុលាការចាប់ពីដំណាក់កាលចាប់ផ្ដើមនៃនីតិវិធីសវនាការ រហូតដល់តុលាការប្រកាសបញ្ចប់ដំណាក់កាលសួរដេញដោលហើយចូលទៅពិចារណាក្នុងបន្ទប់សម្ងាត់ដើម្បីសម្រេចសេចក្ដី ។ លុះពេលតុលាការចេញពីបន្ទប់ពិចារមកប្រកាសសសាលក្រមភាគីចុងចម្លើយ និងមេធាវី ដែលជាតំណាងរបស់ចុងចម្លើយអវត្តមាន ពុំបានស្ដាប់ការប្រកាសសាលក្រមរបស់តុលាការទេ តើចុងចម្លើយ ឬមេធាវីតំណាងរបស់ចុងចម្លើយ ដែលអវត្តមានពេលប្រកាសសាលក្រមនោះ ច្បាប់ផ្ដល់សិទ្ធិឱ្យប្ដឹងទាស់នឹងសាលក្រមរបស់តុលាការនេះឬទេ ឬក៏ផ្ដល់សិទ្ធិឱ្យត្រឹមតែប្ដឹងឧទ្ធរណ៍ ។

ចំពោះបញ្ហានេះ ច្បាប់របស់យើងនៅខ្វះចន្លោះពុំបានចែងឱ្យបានច្បាស់លាស់នោះទេ ប៉ុន្តែផ្អែកតាមខ្លឹមសារមាត្រា១៤១ នៃច្បាប់ស្ដីពីអំពីវិធីព្រហ្មទណ្ឌ ដែលអាចយកទៅអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរនោះភាគីចុងចម្លើយ ឬមេធាវីដែលជាតំណាងរបស់ចុងចម្លើយក្នុងរឿងក្ដីនេះ ពុំមានសិទ្ធិប្ដឹងទាស់នឹងសាលក្រមនេះទេ គឺមានសិទ្ធិត្រឹមតែប្ដឹងឧទ្ធរណ៍ប៉ុណ្ណោះ ប្រសិនបើខ្លួនមិនសុខចិត្តនឹងសេចក្ដីសម្រេចនៃសាលក្រមរបស់តុលាការនេះ ព្រោះគូភាគីបានចូលរួបក្នុងដំណាក់កាលសួរដេញដោលចប់សព្វគ្រប់ហើយ បានន័យថាការជូនសំអាង ឬភស្តុតាងផ្សេងៗសម្រាប់ការពារផលប្រយោជន៍របស់គូភាគីក្នុងរឿងក្ដីនេះ ច្បាប់បានកំណត់ឱ្យតុលាការឈប់ទទួលយកតទៅទៀតហើយ ។

អាស្រ័យហេតុនេះ សូមលោកចៅក្រមជ្រាបតាមការគួរ ។

ភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០០៥
**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍានា**

<u>ចម្លងជូន</u>
-លោកប្រធានតុលាការក្រុងភ្នំពេញ
-លោក ណាច ទ្រី ជាមេធាវី
ដើម្បីជ្រាប